01740236

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.)

## គម្រោងបញ្ចប់ផែនការ

## កំណែលើកទី ៣០

## ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១


**សេចក្តីសង្ខេប** .... 2

I. **សេចក្តីផ្តើម** .... 3

II. **វិធានការដែលអាចជួយបញ្ចប់កិច្ចដំណើរការនីតិវិធីបានឆាប់រហ័ស** .... 9

III. **ផែនការបញ្ចប់ការស៊ើបអង្កេត** .... 11

ក. ការិយាល័យសហចៅក្រមស៊ើបអង្កេត .... 12

ខ. អង្គបុរេជំនុំជម្រះ .... 12

IV. **ផែនការបញ្ចប់សវនាការ** .... 13

V. **ផែនការបញ្ចប់បណ្តឹងសាទុក្ខ** .... 13

ក. សំណុំរឿង០០២/០២ .... 13

ខ. សំណុំរឿង ០០៣ និងសំណុំរឿង ០០៤ .... 14

VI. **សេចក្តីសន្និដ្ឋាន** .... 14

ឧបសម្ព័ន្ធ ៖ តារាងកំណត់ពេលវេលាតាមការគ្រោងទុកសម្រាប់ការបញ្ចប់ផែនការ ដែលរួមមានព្រឹត្តិការណ៍សំខាន់ៗ។


**<u>កំណត់សម្គាល់សម្រាប់អ្នកអាន៖</u>**

គម្រោងបញ្ចប់ផែនការ អ.វ.ត.ក.ត្រូវបានកែសម្រួលរៀងរាល់មួយត្រីមាសម្តងក្នុងគោលបំណងរៀបចំផែនការ។ ខ្លឹមសារនៃគម្រោងនេះរួមមានការប៉ាន់ប្រមាណដ៏ល្អបំផុតនូវពេលវេលាសម្រាប់សំណុំរឿងដែលនៅសេសសល់នៃអ.វ.ត.ក.គិតត្រឹមពេលនៃការកែសម្រួលនេះ។ កត្តាមួយចំនួន ក្នុងនោះរួមមានការវិវត្តនៃដំណើរការនីតិវិធី គឺអាចមានឥទ្ធិពលទៅលើការប៉ាន់ប្រមាណទុកទាំងនេះ។ ហេតុដូច្នេះ ពេលវេលាដែលគ្រោងទុកទាំងឡាយមិនឆ្លុះបញ្ចាំងតម្រូវការតាមផ្លូវច្បាប់ទៅលើព្រឹត្តិការណ៍សំខាន់ខុសៗគ្នានឹងត្រូវសម្រេចនៅពេលណានោះឡើយ។ គម្រោងបញ្ចប់ផែនការអ.វ.ត.ក.ត្រូវបានរៀបចំនិងចេញដោយការិយាល័យរដ្ឋបាលដោយមានការចូលរួមយោបល់ពីការិយាល័យតុលាការទាំងអស់។

## សេចក្តីសង្ខេប

គម្រោងបញ្ចប់ផែនការសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អង្គជំនុំជម្រះ”) ត្រូវបានរៀបចំឡើងជាលើកដំបូងនៅ*ខែមីនា ឆ្នាំ២០១៤* ដោយឆ្លងកាត់ការពិគ្រោះពិភាក្សាយោបល់ពីសំណាក់ការិយាល័យរដ្ឋបាលជាមួយនឹងចៅក្រមនៃអង្គជំនុំជម្រះផ្សេងៗ សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាទាក់ទិននឹងការទទួលខុសត្រូវរបស់ពួកគាត់។ នេះគឺជាការធ្វើបច្ចុប្បន្នភាពប្រចាំត្រីមាសទី៣០ នៃគម្រោងបញ្ចប់ផែនការនេះដែលបញ្ចប់នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១[1]។

ក្នុងកំឡុងត្រីមាសនេះ អង្គជំនុំជម្រះតុលាការកំពូល បានបើកសវនាការលើបណ្តឹងសាទុក្ខ០០២/០២។ អង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណារបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤ ចេញសេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិអំពីភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០៤។

---

[1] គម្រោងបញ្ចប់ផែនការដំបូង និងកំណែទាំងអស់អាចរកមើលបានជាសាធារណៈនៅលើគេហទំព័រ អ.វ.ត.ក។

# I. សេចក្ដីផ្ដើម

១ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អង្គជំនុំជម្រះវិសាមញ្ញ”) បានចាប់ផ្ដើមដំណើរការរបស់ខ្លួននៅខែកុម្ភៈ ឆ្នាំ២០០៦ និងបានដំណើរពេញលេញបន្ទាប់ពីការអនុម័ត *វិធានផ្ទៃក្នុង* នៅក្នុងខែមិថុនា ឆ្នាំ២០០៧។ អណត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បីកាត់សេចក្ដី “មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែ មេសា ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩”[2]។

២ គម្រោងបញ្ចប់ផែនការនេះបានបរិយាយយ៉ាងលម្អិតដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងបរិបទនៃសេចក្ដីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ *A/RES/68/247B* ដែលក្នុងចំណោមបញ្ហាផ្សេងៗទៀត បានកំណត់អាណត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញឲ្យរៀបចំយុទ្ធសាស្ត្របញ្ចប់ ដោយមានផែនទីបង្ហាញផ្លូវច្បាស់លាស់មួយ។ ឯកសារនេះធ្វើឡើងដោយអង្គជំនុំជម្រះវិសាមញ្ញដោយមានការពិគ្រោះយោបល់តាមរយៈការិយាល័យរដ្ឋបាល ជាមួយចៅក្រមអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាអំពីការទទួលខុសត្រូវរបស់ពួកគេ។ អង្គជំនុំជម្រះវិសាមញ្ញធ្វើបច្ចុប្បន្នភាពផែនការបញ្ចប់នេះរៀងរាល់ត្រីមាស។ ឯកសារនេះ គឺជាកំណែលើកទី៣០ ហើយបានបញ្ចូលនូវការកែតម្រូវនានា ដោយផ្អែកលើវឌ្ឍនភាពនៃដំណើរការនីតិវិធីតាមផ្លូវតុលាការដែលកំពុងប្រព្រឹត្តទៅចាប់ពីថ្ងៃទី០១ ខែកក្កដា ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១។

៣ ឯកសារនេះផ្ដោតជាពិសេសលើវឌ្ឍនភាពថ្មីៗ នៅក្នុងសំណុំរឿងដែលនៅសេសសល់ដែលបច្ចុប្បន្នកំពុងស្ថិតនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ និងផ្ដល់នូវព័ត៌មានអំពីប្រភេទនៃរឿងក្ដី ព្រមទាំងស្ថានភាពនៃសំណុំរឿងទាំងនោះ និងជំហាននានាដែលត្រូវបំពេញ មុនពេលកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការបញ្ចប់ជាស្ថាពរតាមផ្លូវច្បាប់។ កិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការក្នុងសំណុំរឿង ០០២

---

[2] *កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣។*

នឹងត្រូវបញ្ចប់នៅពេលមានការវិនិច្ឆ័យស្ថាពរទៅលើសំណុំរឿង០០២/០២[3]។ សហព្រះរាជអាជ្ញាបានថ្លែងជាសាធារណៈថានឹងពុំមានសំណុំរឿងបន្ថែមទៀតទេបន្ទាប់ពីសំណុំរឿង០០៤[4]។ ហេតុដូចនេះ សំណុំរឿងដែលមាននាពេលនេះគឺជាសំណុំរឿងសរុបដែលអង្គជំនុំជម្រះវិសាមញ្ញត្រូវចាត់ការតាមនីតិវិធី។

៤ **សំណុំរឿង០០១** ប្រឆាំងនឹង កាំង ហ្កេចអ៊ាវ (ហៅ ឌុច) គឺជាសំណុំរឿងដំបូងដែលបានជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ។ នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ អង្គជំនុំជម្រះតុលាការកំពូល បានប្រកាសសាលដីការបស់ខ្លួននៅក្នុងបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងធ្វើឲ្យសំណុំរឿងនេះត្រូវបានបញ្ចប់ស្ថាពរ។ ជនជាប់ចោទបានទទួលមរណភាពនៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០ នៅក្នុងមន្ទីរពេទ្យខណៈដែលកំពុងតែអនុវត្តទោសដាក់ពន្ធនាគារអស់មួយជីវិត។

៥ អង្គជំនុំជម្រះបានបំបែកបទចោទនៅក្នុង**សំណុំរឿង ០០២** ទៅជាសវនាការចំនួនពីរ។ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រម នៅក្នុងសវនាការដំណាក់កាលទីមួយដែលមានឈ្មោះថា សំណុំរឿង ០០២/០១ នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ ប្រឆាំងនឹង នួន ជា និង ខៀវ សំផន[5]។ ជនជាប់ចោទចំនួនពីរនាក់ទៀតនៅក្នុងរឿងក្ដី គឺ អៀង សារី បានទទួលមរណភាពនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ និង អៀង ធីរិទ្ធ បានទទួលមរណភាពនៅ និងថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៥ ហេតុដូចនេះ កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងពួកគេត្រូវបានរំលត់។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ខៀវ សំផន និង នួន ជា មានពិរុទ្ធភាពពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៧ និងត្រូវបានផ្ដន្ទាទោសម្នាក់ៗឲ្យជាប់ពន្ធនាគារអស់មួយ

---

[3] នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្ដីសម្រេចដែលសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងអង្គហេតុនានាដែលបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ ដែលមិនត្រូវបានបញ្ចូលទៅក្នុងសំណុំរឿង ០០២/០១ ឬសំណុំរឿង ០០២/០២៖ សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសជ (ឯកសារ E439/5)។

[4] *សេចក្ដីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិស្ដីទីអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មីៗចំនួន២ ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៩។ សេចក្ដីថ្លែងការណ៍សាធារណៈដោយសហព្រះរាជអាជ្ញាទាក់ទិននឹងការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ ចេញផ្សាយថ្ងៃទី០៥ខែមិថុនា ឆ្នាំ២០១២ និងសេចក្ដីថ្លែងការណ៍ដោយសហព្រះរាជអាជ្ញាអន្តរជាតិទាក់ទិននឹងបន្ទុកការងាររបស់ អ.វ.ត.ក ចេញផ្សាយថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤។*

[5] សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសជ (ឯកសារ E313)។

ជីវិត។ ដំណើរការនីតិវិធីបណ្ដឹងសាទុក្ខក្នុងសំណុំរឿងនេះត្រូវបានបញ្ចប់នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ដោយមានការប្រកាសសាលដីកាអង្គជំនុំជម្រះតុលាការកំពូល។ អង្គជំនុំជម្រះតម្កល់សាលក្រមសម្រេចផ្ដន្ទាទោសអស់មួយជីវិតលើជនជាប់ចោទទាំងពីរ[6]។

៦ ការជំនុំជម្រះទីពីរកំពុងដំណើរការក្នុងពេលបច្ចុប្បន្ននេះ ដែលមានឈ្មោះថា សំណុំរឿង ០០២/០២ បានផ្ដោតលើជម្រើសតំណាងបទចោទមួយចំនួនដែលនៅសល់ប្រឆាំងនឹងជនជាប់ចោទ នួន ជា និង ខៀវ សំផន។ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្ដីសង្ខេបផ្ទាល់មាត់ទៅលើសំអាងហេតុនិងសេចក្ដីសម្រេចនៃសាលក្រម នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ និងចេញសាលក្រមទាំង ០៣ ភាសាផ្លូវការ នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩។ អង្គជំនុំជម្រះ រកឃើញថា ខៀវ សំផន និង នួន ជា មានពិរុទ្ធភាពពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយបានផ្ដន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត[7]។

៧ នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៩ នួន ជា ទទួលមរណភាពក្នុងអាយុ៩៣ឆ្នាំ ខណៈដែលកំពុងទទួលការព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ចប់កិច្ចដំណើរការនីតិវិធីបណ្ដឹងសាទុក្ខប្រឆាំងនឹង នួន ជា នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ និងបានបំភ្លឺបញ្ជាក់ថា ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹង នួន ជា។ កិច្ចដំណើរការនីតិវិធីលើបណ្ដឹងសាទុក្ខបន្តទៅក្នុងសំណុំរឿង ០០២/០២ ប្រឆាំងនឹង ខៀវ សំផន តែម្នាក់ប៉ុណ្ណោះ។

៨ កិច្ចស៊ើបសួរនៅក្នុង**សំណុំរឿង ០០៣** (ពាក់ព័ន្ធនឹង មាស មុត) និង **សំណុំរឿង ០០៤** បានផ្ដួចផ្ដើមឡើងក្រោយពេលសហព្រះរាជអាជ្ញាអន្តរជាតិចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនៅក្នុងឆ្នាំ ២០០៩ ហើយបន្ទាប់មកចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។ បន្ទាប់មក សហចៅក្រមស៊ើបអង្កេតបានបំបែកសំណុំរឿង ០០៤ ចេញជាសំណុំរឿងចំនួនបី៖ *សំណុំរឿង ០០៤/០១* ពាក់ព័ន្ធនឹង អ៊ឹម ចែម *សំណុំរឿង ០០៤/០២* ពាក់ព័ន្ធនឹង អោ អាន និង សំណុំរឿងដែលនៅសេសសល់ គឺ សំណុំរឿង ០០៤ ប្រឆាំងនឹង យឹម ទិត្យ។

[6] សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជតក (ឯកសារ F36)។

[7] សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសជ (ឯកសារ E465)។

៩ នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ ដោយមានសំអាងហេតុលើកលែងចោទប្រកាន់សំណុំរឿង ០០៤/០១ ប្រឆាំងនឹង អ៊ឹម ចែម។ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៅមុខអង្គបុរេជំនុំជម្រះ។ នៅថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៨ អង្គបុរេជំនុំជម្រះបានសម្រេចលើបណ្តឹងឧទ្ធរណ៍ ដោយប្រកាសជាអាទិ៍ថាសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលថា អង្គជំនុំជម្រះវិសាមញ្ញមិនមានយុត្តាធិការលើ អ៊ឹម ចែម ចាត់ទុកជាបានការដែលជាការបញ្ចប់ដំណើរការនីតិវិធីតុលាការ ក្នុងសំណុំរឿងនេះ[8]។

១០ នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា នៅក្នុងសំណុំរឿង ០០៤/០២ ប្រឆាំងនឹង អោ អាន។ អង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណារបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ដោយប្រកាសថាអង្គជំនុំជម្រះ “មិនអាចទទួលបានសម្លេងគាំទ្រ យ៉ាងតិចបួនសំឡេង សម្រាប់ចេញសាលដីកា ផ្អែកលើសំអាងហេតុរួមគ្នា លើអង្គសេចក្តីបានឡើយ”[9]។ សំណុំរឿងប្រឆាំង អោ អាន ត្រូវបានបញ្ជូនទៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ដោយផ្អែកលើមូលដ្ឋានថា ពុំមាន “ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលជាក់លាក់ និងអាចអនុវត្តបាន”[10]។ សំណុំរឿង ០០៤/០២ ត្រូវបានបោះត្រា និងដាក់ទៅក្នុងបណ្ណសារ ដោយដីកាតុលាការនៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ ដោយបញ្ចប់កិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការលើសំណុំរឿងនេះ[11]។

១១ ដំណើរការនីតិវិធីសំណុំរឿង០០៣ និងសំណុំរឿង០០៤ មានវឌ្ឍនភាព ដូចខាងក្រោម៖

ក- នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយចំនួនពីរដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា ក្នុងសំណុំរឿង០០៣ ប្រឆាំង មាស មុត។ បណ្តឹងឧទ្ធរណ៍ចំនួនបីត្រូវបានដាក់ប្រឆាំងនឹងដីកាដំណោះស្រាយ។ មេធាវីការពារក្តី និងសហព្រះរាជអាជ្ញាជាតិបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនរឿងទៅ

---

[8] សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩/អវតក/កសចស (អបជ៥០) (ឯកសារ D308/3/1/20)។

[9] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩/អវតក/កសចស (អបជ៦០) (ឯកសារ D359/24-D360/33)។

[10] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩/អវតក/អជសជ/អជតក (ឯកសារ E004/2/1/1/2)។

[11] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩/អវតក/កសចស (ឯកសារ D363/3)។

ជំនុំជម្រះ)។ ចំណែកឯសហព្រះរាជអាជ្ញាអន្តរជាតិប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ[12]។ អង្គបុរេជំនុំជម្រះបានដាក់សេចក្តីពិចារណារបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៩ ដោយថ្លែងថា អង្គបុរេជំនុំជម្រះ "មិនអាចរកសំឡេងភាគច្រើនលើសលប់នៃសំឡេងគាំទ្រចំនួនបួនតាមការកំណត់ ដើម្បីឈានទៅដល់ការធ្វើសេចក្តីសម្រេចមួយលើអង្គសេចក្តី ផ្អែកលើសំអាងហេតុរួមបានឡើយ"[13]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបដិសេធសំណើបន្ទាប់របស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងការបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ដោយសន្និដ្ឋានថា "ទាំងភាពជាឯកច្ឆន្ទ ក៏ដូចជាសំឡេងភាគច្រើនលើសលប់ គឺមិនមានឡើយនៅក្នុងចំណោមចៅក្រម អ.ប.ជ សម្រាប់[ដីកាសំណោះស្រាយ]ណាមួយក្នុងសំណុំរឿង០០៣"និងថាហេតុដូច្នេះពុំមានមូលដ្ឋានក្នុងការបញ្ជូនសំណុំរឿងទៅជំនុំជម្រះបានឡើយ[14]។ ក្រោយពីមានសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សហមេធាវីការពារក្តី មាស មុត បានដាក់សំណើជូនអង្គបុរេជំនុំជម្រះស្នើសុំ បញ្ចប់ បោះត្រា និងដាក់បញ្ចូលសំណុំរឿង០០៣ទៅក្នុងបណ្ណសារ[15] ខណៈដែលសហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំឲ្យអង្គបុរេជំនុំបិទបញ្ចប់ដំណើរការ មុនការជំនុំជម្រះ ដោយបញ្ជាក់ថា មាស មុត ត្រូវបានចោទប្រកាន់និងបង្គាប់ឲ្យនាំខ្លួនគាត់ទៅជំនុំជម្រះ[16]។ នៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ អង្គជំនុំជម្រះប្រកាសថា សំណើទាំងនេះមិនអាចទទួលយកបាន ដោយថ្លែងថា "អំណើះតទៅ សហចៅក្រមគួរតែអនុវត្តតាម [សេចក្តីពិចារណា] ភ្លាមៗជាបន្ទាន់"[17]។ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ សហចៅក្រមស៊ើបអង្កេតបានស្នើសហព្រះរាជអាជ្ញា អន្តរជាតិប្រកាសថាតើ ខ្លួនមានបំណងប្តឹងសារទុក្ខឬទេ[18]។ សហព្រះរាជអាជ្ញាអន្តរជាតិផ្តល់ចម្លើយវិជ្ជមាន[19]។ នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២១ អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់សហព្រះរាជអាជ្ញាអន្តរជាតិ

[12] ប្រវត្តិនីតិវិធីពេញលេញ អាចរកមើលបាននៅក្នុងគម្រោងបញ្ចប់ផែនការ កំណែទី២៧។

[13] សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ៣៥) (ឯកសារ D266/27- D267/35)។

[14] សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អវតក/កសចស (ឯកសារ D270/7)។

[15] សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ៣៨) (ឯកសារ D272)។

[16] សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ៣៧) (ឯកសារ D271/1)។

[17] សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ៣៧, អបជ៣៨) (ឯកសារ D271/5-D272/3)។

[18] សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អវតក/កសចស(ឯកសារ D273)។

[19] សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អវតក/កសចស(ឯកសារ D273/1)។

ឲ្យដាក់សំណើជាពីរភាសា អនុលោមតាមក្របខណ្ឌគតិយុត្ត[20]។ សំណុំរឿង០០៣ នៅរង់ចាំការសម្រេចនៅចុងត្រីមាសនេះ។

ខ- នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា ក្នុងសំណុំរឿង ០០៤ ប្រឆាំងនឹង យឹម ទិត្យ។ បណ្តឹងឧទ្ធរណ៍ចំនួន ០៥ ត្រូវបានដាក់ប្រឆាំងនឹងដីកាដំណោះស្រាយ៖ មេធាវីការពារក្តី និងសហព្រះរាជអាជ្ញាជាតិបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) សហព្រះរាជអាជ្ញាអន្តរជាតិ និងដើមបណ្តឹងរដ្ឋប្បវេណីបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាលើកលែងការចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ ហើយមេធាវីការពារក្តី ក៏បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការចេញដីកាដំណោះស្រាយដោយឡែកពីគ្នាផងដែរ[21]។ នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ អង្គជំនុំជម្រះបានចេញសេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ដោយប្រកាសថា “មិនអាចរកសំឡេងគាំទ្រពីចៅក្រមបួនរូបយ៉ាងតិច ដើម្បីចេញសាលដីកាមួយទៅលើអង្គសេចក្តី ដោយផ្អែកលើសំអាងហេតុរួមបានឡើយ”[22]។ នៅថ្ងៃទី២៣ ខែកញ្ញា សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំបន្ថែមពេលវេលាក្នុងការដាក់ពាក្យសុំក្នុងសំណុំរឿង០០៤ នៅអង្គជំនុំជម្រះ តុលាការកំពូល[23]។ សំណុំរឿង ០០៤ រង់ចាំការសម្រេចនៅចុងត្រីមាសនេះ។

១២ តាមរយៈការវិវត្តក្នុងត្រីមាសចុងក្រោយនេះ គម្រោងបញ្ចប់ផែនការរបស់អង្គជំនុំជម្រះវិសាមញ្ញកំណត់ព្រឹត្តិការណ៍សំខាន់ចំនួនបីសម្រាប់សំណុំរឿងដែលអង្គជំនុំជម្រះបានទទួល។ ព្រឹត្តិការណ៍សំខាន់ដែលនៅសេសសល់ចំនួនពីរនៅក្នុងសំណុំរឿង០០២ និង ការព្យាករណ៍ ដែលពាក់ព័ន្ធគឺ៖

(i) ការចេញសាលដីកាជាភាសាផ្លូវការទាំងបីភាសា (ត្រីមាសទី៤ ឆ្នាំ២០២២)។

---

[20] សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អវតក/អជតក (ពុំទាន់មានលេខឯកសារ)។

[21] ប្រវត្តិនីតិវិធីពេញលេញ អាចរកមើលបាននៅក្នុងគម្រោងបញ្ចប់ផែនការ កំណែទី២៧។

[22] សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ៦១) (ឯកសារ D381/45-D382/43)។

[23] ដោយយោងលើសេចក្តីសម្រេចរបស់ខ្លួន ចុះថ្ងៃទី២២ ខែកញ្ញា (មើលលេខជើងទំព័រ២០) នៅថ្ងៃទី០៤ ខែតុលា អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ឲ្យសហព្រះរាជអាជ្ញាអន្តរជាតិដាក់សារណាជាពីរភាសា ដោយពុំកំណត់កាលបរិច្ឆេទ។

១៣ នៅក្នុងសំណុំរឿង០០៣ និងសំណុំរឿង០០៤ ព្រឹត្តិការណ៍ដ៏សំខាន់សរុបចំនួន០២ ត្រូវបានកំណត់សម្រាប់ដំណាក់កាលបណ្តឹងឧទ្ធរណ៍លើកិច្ចស៊ើបសួរ។ ក្នុងករណីសំណុំរឿងត្រូវបានបញ្ជូនទៅជំនុំជម្រះ មានព្រឹត្តិការណ៍សំខាន់បន្ថែមទៀតសម្រាប់ដំណាក់កាលជំនុំជម្រះនិងបណ្តឹងសាទុក្ខ[24]។ ព្រឹត្តិការណ៍សំខាន់សម្រាប់ដំណាក់កាលបណ្តឹងឧទ្ធរណ៍លើកិច្ចស៊ើបសួរដែលបន្តនៅសេសសល់ គឺ៖

(ii) ការអនុវត្តសេចក្តីពិចារណាដោយអង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង០០៣ ថាតើត្រូវបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធីក្នុងសំណុំរឿងនោះ (ត្រីមាសទី៤ ឆ្នាំ២០២១) និង

(iii) ការអនុវត្តសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ទៅលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង០០៤ ថាតើបញ្ជូនសំណុំរឿងទៅជម្រះ ឬក៏បញ្ចប់កិច្ចនីតិវិធី (ត្រីមាសទី៤ ឆ្នាំ ២០២១)។

## II. វិធានការដែលអាចជួយបញ្ចប់កិច្ចដំណើរការនីតិវិធីបានឆាប់រហ័ស

១៤ ដំណើរការប្រកបដោយប្រសិទ្ធិភាពរបស់អង្គជំនុំជម្រះវិសាមញ្ញកន្លងទៅត្រូវបានរំខាន ដោយភាពមិននឹងនផ្នែកហិរញ្ញវត្ថុដែលចេះតែបន្តកើតមាន ដែលបណ្តាលឲ្យបុគ្គលិកជាតិធ្វើកូដកម្មមិនធ្វើការចំនួនពីរលើកក្នុងអំឡុងឆ្នាំ២០១៣ ព្រមទាំងបុគ្គលិកចេញចូលពីមុខតំណែងដោយមិនសមហេតុផល។ ការអនុម័តរបស់ មហាសន្និបាតទៅលើឧបត្ថម្ភធនសម្រាប់ឆ្នាំសារពើពន្ធ ២០១៤-២០២០ សម្រាប់ភាគីអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញ គឺជាវិធានការដ៏សំខាន់ដែលបានធ្វើឲ្យមានស្ថិរភាពដល់ស្ថានភាពថវិកានិងធ្វើឲ្យមានការផ្តោតមូលទៅ លើការធ្វើឲ្យវិវត្តទៅមុខនៃអាណត្តិតុលាការ។ ចំពោះភាគីជាតិវិញ ការលំបាកផ្នែកលំហូរសាច់ប្រាក់បាននាំឲ្យមានការពន្យារពេលបើកប្រាក់បៀវត្សសម្រាប់បុគ្គលិកជាតិនៅក្នុងកំឡុងពាក់កណ្តាលឆ្នាំ២០១៥ ដែលប៉ះពាល់ដល់ការផ្តោតអារម្មណ៍ និងទឹកចិត្តបំពេញការងារ។

---

24 ដោយសារស្ថានភាពនៃកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន នៅពេលនេះយើងមិនអាចព្យាករចំណុចពេលវេលាជាក់លាក់ទាក់ទិននឹងគ្រោងការជំនុំជម្រះក្តីបានឡើយ។

១៥ ក្រោយពីមានការសម្តែងនូវការគាំទ្រពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា មហាសន្និបាតអង្គការសហប្រជាជាតិ ក្នុងលក្ខណៈជាវិធានការពិសេសបានអនុញ្ញាតឱ្យអគ្គលេខាធិការសម្រេចកំណត់ទឹកប្រាក់ចំនួនមិនលើស ៧ លានដុល្លារ នៅក្នុងខែធ្នូ ឆ្នាំ២០២០ ដើម្បីបន្ថែមបង្គ្រប់ធនធានថវិកាស្ម័គចិត្តរបស់ភាគីអន្តរជាតិ នៃអង្គជំនុំជម្រះវិសាមញ្ញសម្រាប់រយៈពេលគិតចាប់ពីថ្ងៃទី០១ ខែមករា ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។ គិតមកត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ថវិកាត្រូវបានដកប្រើប្រាស់អស់ហើយ។ សកម្មភាពទាន់ពេលវេលានេះបានជួយសម្រួលយ៉ាងច្រើនដល់ប្រតិបត្តិការនៅអង្គជំនុំជម្រះវិសាមញ្ញមិនឱ្យរអាក់រអួល ក្នុងអំឡុងឆមាសទី១ ក្នុងឆ្នាំ២០២១ ដោយបើកឱកាសឱ្យមានការរៃអង្គាសថវិកាស្ម័គ្រចិត្តបន្តទៀត។ ជាងនេះទៀត ការសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការផ្តល់វិភាគទានដោយផ្ទាល់ចំនួន ៣,៦ លានដុល្លារ ដើម្បីចំណាយទៅលើប្រាក់បៀវត្សបុគ្គលិកជាតិ ០៦ ខែដំបូងក៏ដូចជាចំណាយប្រតិបត្តិការសម្រាប់ឆ្នាំ២០២១ គឺជាវិធានការដ៏សំខាន់ដែលជួយដល់ប្រតិបត្តិការបច្ចុប្បន្នរបស់ភាគីជាតិនៃអង្គជំនុំជម្រះវិសាមញ្ញ។ ដោយរួមបញ្ចូលគ្នាបែបនេះ វិធានការទាំងនេះធានាថា ទំហំការងារបច្ចុប្បន្នរបស់អង្គជំនុំជម្រះវិសាមញ្ញ បានបន្តទទួលបាននូវការយកចិត្តទុកដាក់ជានិច្ច និងការផ្តល់ថវិកា។ វិភាគទានស្ម័គ្រចិត្តដែលទទួលបាន ឬដែលបានសន្យា សម្រាប់ឆ្នាំ២០២១ គិតមកត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ មានចំនួន ៣,៦ លានដុល្លារ សម្រាប់ភាគីអន្តរជាតិ និងចំនួន ១,២ លានដុល្លារសម្រាប់ភាគីជាតិ។ ថវិកានេះដើម្បីបង្គ្រប់តាមតម្រូវការថវិកាដែលបានកែសម្រួលសម្រាប់ឆ្នាំ២០២១ ចំនួន ១២,៩ លានដុល្លារសម្រាប់ភាគីអន្តរជាតិ និង ៤,៩ លានដុល្លារសម្រាប់ភាគីជាតិ[25]។

១៦ ក្នុងខែមករា ឆ្នាំ២០១៥ កិច្ចប្រជុំពេញអង្គរបស់អង្គជំនុំជម្រះវិសាមញ្ញ បានអនុម័តវិសោធនកម្មទៅលើវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ ដែលអនុញ្ញាតឱ្យមានការកាត់បន្ថយទៅលើវិសាលភាពកិច្ចស៊ើបសួរ ល្គឹកណាវិសាលភាពស៊ើបអង្កេតដែលបានកាត់បន្ថយជាតំណាងឱ្យបទចោទ និងការទទួលខុសត្រូវ ព្រហ្មទណ្ឌរបស់ជនសង្ស័យតាមការចោទប្រកាន់[26]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកាត់បន្ថយ វិសាលភាពនៃកិច្ចស៊ើបសួរពាក់ព័ន្ធនឹង មាស មុត ក្នុងសំណុំរឿង០០៣, អោ អាន ក្នុងសំណុំរឿង ០០៤/០២ និង យឹម ទិត្យ ក្នុងសំណុំរឿង ០០៤ អនុលោមតាមបទបញ្ញត្តិនេះ។ ស្រដៀង

---

[25] តួលេខថវិកាដែលបានកែសម្រួលសម្រាប់ឆ្នាំ២០២០-២០២១ ត្រូវបានគាំទ្រដោយក្រុមបណ្តាប្រទេសដែលមានចំណាប់អារម្មណ៍នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០។

[26] វិធាន៦៦ស្ទួន។

01740246

គ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិអំណាច កាត់បន្ថយវិសាលភាពនៃការជំនុំជម្រះក្តីមួយ ដោយមិនរួមបញ្ចូលអង្គហេតុជាក់លាក់មួយចំនួន ដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដរាបណាអង្គហេតុដែលនៅសល់ដែលត្រូវជម្រះ គឺជាតំណាងវិសាលភាពនៃដីកាបញ្ជូនរឿងទៅជម្រះ[27]។ ឈរលើមូលដ្ឋាននេះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ចប់កិច្ចនីតិវិធីពាក់ព័ន្ធនឹងអង្គហេតុដែលមានចែងក្នុងសំណុំរឿង ០០២ ដែលមិនមានបញ្ចូលនៅក្នុងសំណុំរឿង ០០២/០១ ឬសំណុំរឿង ០០២/០២។

១៧ ការិយាល័យរដ្ឋបាលបានចុះកិច្ចសន្យាផ្នែកសេវាកម្មបុគ្គលិកឯកទេសនីតិសាស្ត្រមួយចំនួនជាលក្ខណៈទីប្រឹក្សា ដើម្បីសម្របសម្រួលដល់ការធ្វើសេចក្តីព្រាងសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង០០២/០២ និងបានបន្តធ្វើការជាមួយបុគ្គលិផ្នែកភាសាដើម្បីធានាសេវាបកប្រែបានទាន់ពេលវេលា។

១៨ ដើម្បីទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩ *ការរៀបចំបែបផែនការងារជាជម្រើសផ្សេង* ត្រូវបានដាក់ចេញអនុវត្តសម្រាប់គ្រប់បុគ្គលិកទាំងអស់នៅ អ.វ.ត.ក នៅចន្លោះថ្ងៃទី១ និងថ្ងៃទី៥ ខែមករា និងម្តងទៀតចាប់ពីថ្ងៃទី២៣ ខែកុម្ភៈ រហូតដល់រយៈពេលរាយការណ៍នេះ[28]។ រាល់ធនធានបណ្តាញទាំងអស់ ទាំងផ្នែករដ្ឋបាល ព្រមទាំងផ្នែកតុលាការ ត្រូវបានផ្តល់ដល់បុគ្គលិកទាំងអស់ពីចម្ងាយ ក្នុងគោលបំណងជួយសម្រួលដល់និរន្តភាពដំណើរការរដ្ឋបាល និងតុលាការ។

## III. ផែនការបញ្ចប់ការស៊ើបអង្កេត

១៩ ដំណាក់កាលស៊ើបអង្កេតរួមមានយុត្តាធិការរបស់ (ក) ការិយាល័យសហចៅក្រមស៊ើបអង្កេត និង (ខ) អង្គបុរេជំនុំជម្រះនៅដំណាក់កាលបណ្តឹងឧទ្ធរណ៍។

---

[27] វិធាន៨៩ *ស្ទួន៣*។

[28] ការរៀបចំទាំងនេះណែនាំដល់បុគ្គលិកទាំងអស់ឲ្យបំពេញការងារពីចម្ងាយ ពីកន្លែងមួយនៅក្នុង ឬខាងក្រៅការិយាល័យ។ សូមមើលគោលការណ៍ណែនាំផ្នែករដ្ឋបាលសម្រាប់ការិយាល័យស្តីពីការរាលដាលនៃជំងឺកូរ៉ូណាថ្មី (កូវីដ១៩) (កថាខណ្ឌ១៤ និង២២ នៃ *កំណែលើកទី១ នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០* និងកថាខណ្ឌ ១៥ និង ២៦ នៃ *កំណែលើកទី៤* បច្ចុប្បន្ន *នៅថ្ងៃទី១៤ ខែមេសា ឆ្នាំ ២០២០*)។ សម្រាប់ឆ្នាំ២០២០ ការរៀបចំទាំងនេះ ត្រូវបានដាក់ឲ្យអនុវត្តនៅចន្លោះថ្ងៃទី២៥ ខែមីនា និងថ្ងៃទី០១ ខែធ្នូ និងចាប់ពីថ្ងៃទី០៨ ខែធ្នូ រហូតដល់ដាច់ឆ្នាំ។

01740247

## ក. *ការិយាល័យសហចៅក្រមស៊ើបអង្កេត*

២០ អាណត្តិកំណត់ដោយច្បាប់របស់សហចៅក្រមស៊ើបអង្កេតនឹងត្រូវបញ្ចប់នៅពេលសំណុំរឿង០០៣ និង សំណុំរឿង០០៤ ត្រូវបានសម្រេចជាស្ថាពរ។

## ខ. *អង្គបុរេជំនុំជម្រះ*

២១ ក្នុងពេលចាប់ផ្តើមត្រីមាសទី៣ ឆ្នាំ២០២១ អង្គបុរេជំនុំជម្រះបានទទួលបណ្តឹងចំនួន ០៩ ពោលគឺ សំណើបន្ទាន់បង្ខំចំនួន ២ ក្នុងសំណុំរឿង ០០៣, សំណើបន្ទាន់បង្ខំចំនួន ១ និងបណ្តឹងឧទ្ធរណ៍ចំនួន ៦ (មួយករណីពាក់ព័ន្ធនឹងការទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីនិងបណ្តឹងឧទ្ធរណ៍ចំនួន ៥ ទៀតពាក់ព័ន្ធ នឹងដីកាដំណោះស្រាយ) ក្នុងសំណុំរឿង០០៤[29]។ ក្នុងអំឡុងត្រីមាសនេះ អង្គជំនុំជម្រះបានសម្រេចលើ សំណើបន្ទាន់បង្ខំចំនួន ២ ក្នុងសំណុំរឿង០០៣[30] បានចេញសេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍លើ ដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤[31] និងបានចេញសេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំង នឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើភាពទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជា ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០៤[32]។ ពុំមានសំណើរង់ចាំការសម្រេចនៅមុខអង្គបុរេជំនុំ ជម្រះនៅចុងត្រីមាសនេះឡើយ។

---

[29] សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អវតក/កសចស៖ ឯកសារ D271/1 (អបជ៣៧), D272 (អបជ៣៨)។ សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ៦១)៖ ឯកសារ D381/18-D382/21, D381/19, D381/20, D381/29, D382/4/1, D382/22, D384/5។ ឯកសារសំណុំរឿង ០០៤ ទាំងអស់រៀបរាប់ខាងលើនេះត្រូវបានអង្គជំនុំជម្រះចាត់ចំណាត់ថ្នាក់ជាឯកសារ សម្ងាត់។

[30] សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អវតក/កសចស៖ ឯកសារ D271/5-272/3 (អបជ៣៧-៣៨)។

[31] សូមមើលខាងលើ កថាខណ្ឌទី ១១.ក។

[32] សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អវតក/កសចស៖ (អបជ៦២) (ឯកសារD384/7269/4)។ អង្គបុរេជំនុំជម្រះ "មិនអាច រកសំឡេងភាគច្រើនលើសលប់នៃសំឡេងគាំទ្រចំនួនបួនតាមការកំណត់ ដើម្បីឈានទៅដល់ការធ្វើសេចក្តីសម្រេចមួយ លើអង្គសេចក្តី ផ្អែកលើសំអាងហេតុរួមបានឡើយ"។ ចៅក្រមជាតិ និង ចៅក្រមអន្តរជាតិបានភ្ជាប់មកជាមួយនូវយោបល់រៀងៗខ្លួន ទៅលើសេចក្តី សម្រេចនោះ។ចៅក្រមជាតិពិចារណាឃើញថាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីគួរត្រូវបានបដិសេធ ចំណែកឯចៅក្រមអន្តរជាតិ បានពិចារណាឃើញថាអ្នកដាក់ពាក្យសុំចំនួន១៤នាក់គួរតែត្រូវបានសម្រេចទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤ បន្ថែមលើអ្នកដាក់ពាក្យសុំដែលត្រូវបានសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានទទួលស្គាល់។ ពុំមានការចេញសេចក្តីសម្រេចដោយ

## IV. ផែនការបញ្ចប់សវនាការ

២២ រង់ចាំរហូតដល់មានសេចក្តីសម្រេចចុងក្រោយរបស់អង្គបុរេជំនុំជម្រះថាតើសំណុំរឿងទាំងពីរ ឬណាមួយនៃ**សំណុំរឿង០០៣** និង/ឬ **សំណុំរឿង ០០៤** ត្រូវបញ្ជូនទៅជំនុំជម្រះ ទើបអាចមានការប៉ាន់ប្រមាណលើពេលវេលាដែលត្រូវការដើម្បីបញ្ចប់សវនាការទាំងនេះ។ ការវាយតម្លៃទៅលើពេលវេលាដែលត្រូវការអាចនឹងពឹងផ្អែកលើចំនួនចុងចោទ និងភាពស្មុគស្មាញនៃអង្គហេតុ និងអង្គច្បាប់នៃបទចោទទាំងឡាយដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះផង។

## V. ផែនការបញ្ចប់បណ្តឹងសាទុក្ខ

### ក. *សំណុំរឿង០០២/០២*

២៣ នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាបានដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមជំនុំជម្រះដោយមានមូលដ្ឋានចំនួនមួយ[33]។ មេធាវីការពារក្តី ខៀវ សំផន បានដាក់បណ្តឹងសាទុក្ខរបស់ខ្លួនជាភាសាបារាំង នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០[34]។ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបរបស់ខ្លួនតែមួយភាសា នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ ហើយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់ចម្លើយតបរបស់ខ្លួនតែមួយភាសានៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០២១[35]។ ការឆ្លើយ

---

សំឡេងភាគច្រើនលើសលប់ពីចៅក្រមចំនួន៤រូបឡើយទៅលើទំនាក់ទំនងនៃសេចក្តីសម្រេចនេះ ឬភាពពាក់ព័ន្ធផ្នែកច្បាប់ចំពោះសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតជាតិក្នុងការបដិសេធដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលមិនត្រូវបានប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះនោះឡើយ។

[33] សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក/អជសដ (ឯកសារ F50)។ មេធាវីការពារក្តីឆ្លើយតបនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ (សូមមើល ឯកសារ F50/1)។

[34] សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/អជតក (ឯកសារ F54)។ សំណៅបកប្រែជាភាសាខ្មែរត្រូវបានដាក់នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០។ ពេលវេលាក្នុងការដាក់ឯកសារនេះ និងសំណៅបកប្រែនៃឯកសារនេះ ត្រូវបានពន្យល់យ៉ាងលម្អិតនៅក្នុងគម្រោងបញ្ចប់ផែនការ កំណែទី២៧។

[35] សហព្រះរាជអាជ្ញា៖ សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជតក (ឯកសារ F54/1)។ សំណៅបកប្រែជាភាសាខ្មែរត្រូវបានជូនដំណឹងនៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជតក (ឯកសារ F54/2)។ សំណៅបកប្រែជាភាសាខ្មែរ ត្រូវបានជូនដំណឹងនៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២១។

តបទៅនឹងចម្លើយតបទាំងនោះ ត្រូវបានបើកសវនាការផ្ទាល់មាត់ចាប់ពីថ្ងៃទី១៦ រហូតដល់ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១។

២៤ អង្គជំនុំជម្រះតុលាការកំពូលរំពឹងថា សាលដីកានឹងត្រូវចេញទាំងបីភាសាផ្លូវការនៅត្រឹមត្រីមាសទី៤ ឆ្នាំ២០២២។ ការព្យាករណ៍នេះគឺអាស្រ័យលើភាពស្មុគស្មាញនិងតម្រូវការនៃដំណើរការបណ្ដឹងសាទុក្ខ និងកត្តាពាក់ព័ន្ធនានា ដូចជា បុគ្គលិកគ្រប់គ្រាន់ សុខភាព និងសម្បទារបស់ជនជាប់ចោទ ព្រមទាំងសេវាបកប្រែឯកសារទាន់ពេលវេលានិងមានប្រសិទ្ធភាព។

## ខ. *សំណុំរឿង ០០៣ និងសំណុំរឿង ០០៤*

២៥ ប្រសិនបើសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ បន្តទៅមុខរហូតដល់ដំណាក់កាលជំនុំជម្រះនោះ បណ្ដឹងឧទ្ធរណ៍ភ្លាមៗ ឬបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះ សាលាដំបូងអាចកើតឡើង។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ដោយហេតុថាយើងមិនដឹងថាសំណុំរឿងណាមួយដំណើរការរហូតដល់ដំណាក់កាលជំនុំជម្រះ និងមិនដឹងពីបទចោទណាខ្លះនោះ វាហាក់ដូចជាឆាប់ពេកក្នុងការផ្ដល់នូវការប៉ាន់ស្មានចំពោះពេលវេលាដែលតម្រូវក្នុងការសម្រេចលើបណ្ដឹងសាទុក្ខណាមួយនៃសំណុំរឿងពាក់ព័ន្ធ។

## VI. សេចក្ដីសន្និដ្ឋាន

២៦ សម្រាប់*ឆ្នាំ២០២១* ព្រឹត្តិការណ៍សំខាន់ពីរត្រូវបានរំពឹងទុកគឺ ការអនុវត្តសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍លើដីកាដំណោះស្រាយក្នុង (i) សំណុំរឿង ០០៣ ប្រឆាំង មាស មុត និង (ii) សំណុំរឿង០០៤ ប្រឆាំង យឹម ទិត្យ ថាតើត្រូវបញ្ជូនសំណុំរឿងទាំងនេះទៅជំនុំជម្រះ ឬបញ្ចប់កិច្ចដំណើរការនីតិវិធី។

២៧ សម្រាប់*ឆ្នាំ២០២២* ព្រឹត្តិការណ៍សំខាន់មួយត្រូវបានរំពឹងទុកគឺ (iii) ការចេញសាលដីកាក្នុងសំណុំរឿង ០០២/០២ ដោយអង្គជំនុំជម្រះតុលាការកំពូល។

២៨ ប្រសិនបើសំណុំរឿង ០០៣ និង/ឬសំណុំរឿង ០០៤ ត្រូវបញ្ជូនទៅជំនុំជម្រះទាំងមូល ឬដោយផ្នែក ពេលវេលាកំណត់សម្រាប់សំណុំរឿងទាំងនេះនឹងត្រូវព្យាករណ៍នៅពេលនោះ។

២៩ ព្រឹត្តិការណ៍សំខាន់ៗដែលបានគ្រោងទុក មានបង្ហាញជូនក្នុងតារាងដែលភ្ជាប់ជាមួយនឹងផែនការនេះ។

# តារាងកំណត់ពេលវេលាតាមការគ្រោងទុកដែលរួមមានព្រឹត្តិការណ៍សំខាន់ៗ

គម្រោងបញ្ចប់ផែនការ កំណែលើកទី ៣០ - ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១

| សំណុំរឿង | ២០១៨ | | | | ២០១៩ | | | | ២០២០ | | | | ២០២១ | | | | ២០២២ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | ត្រីមាស៤ | ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | ត្រីមាស៤ | ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | ត្រីមាស៤ | ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | ត្រីមាស៤ | ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | ត្រីមាស៤ |
| សំណុំរឿង០០២/០២ នៀវ សំផន | | | ដំណាក់កាលជំនុំជម្រះ | (ខ) | (គ) | | | | (ឃ) | | | | ដំណាក់កាលបណ្តឹងសាទុក្ខ | | | | | | | (ង) |
| សំណុំរឿង០០៣ មាស មុត | | | ដំណាក់កាលស៊ើបអង្កេត | (ច) | (ឆ) | | | | បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ | | | | | | (ជ) | (ឈ) | | | | |
| សំណុំរឿង០០៤ យឹម ទិត្យ | | | ដំណាក់កាលស៊ើបអង្កេត | | | (ច) | (ឆ) | | | | បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ | | | | (ជ) | (ឈ) | | | | |

(ក) សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល (មុនឆ្នាំ២០១៨)

(ខ) សាលក្រម - សេចក្តីសង្ខេប និងផ្នែកសម្រេចសេចក្តី

(គ) សាលក្រម - សំអាងហេតុពេញលេញជាបីភាសា

(ឃ) កាលបរិច្ឆេទកំណត់សម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម

(ង) សាលដីកា

(ច) ដីកាដំណោះស្រាយដាច់ដោយឡែកតែមួយភាសា

(ឆ) ដីកាដំណោះស្រាយដាច់ដោយឡែកជាភាសាអង់គ្លេស និងភាសាខ្មែរ

(ជ) សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទៅលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ

(ឈ) សេចក្តីសម្រេចលើការអនុវត្តសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ